**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានព័ត៌មាន**

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា-ចិន នឹងជំរុញកិច្ចសហប្រតិបត្តិការ ដើម្បីកសាងអនាគតរួម

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម វ៉ាង វិនពីន (Wang Wenbin) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា បានសម្តែងការពេញចិត្តចំពោះស្ថានភាពបច្ចុប្បន្ននៃទំនាក់ទំនងទ្វេភាគីដ៏យូរអង្វែង និងពហុសណ្ឋានរវាងប្រទេសទាំងពីរ នៅក្នុងជំនួបសម្តែងការគួរសមរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២៤ នៅទីស្តីការក្រសួង។ នៅក្នុងជំនួបនោះ ឯកឧត្តមឯកអគ្គរដ្ឋទូត បានពាំនាំនូវការអបអរសាទរយ៉ាងកក់ក្តៅរបស់ឯកឧត្តម វ៉ាង យី សមាជិកការិយាល័យនយោបាយបក្សកុម្មុយនិស្តចិន ប្រធានការិយាល័យគណៈកម្មការកិច្ចការបរទេស និងជារដ្ឋមន្ត្រីការបរទេសរបស់សាធារណរដ្ឋប្រជាមានិតចិន ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ដែលត្រូវបានតែងតាំងជាថ្មី ជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានគូសបញ្ជាក់ពីសេចក្តីរីករាយឥតឧបមា និងការត្រៀមបន្តទំនាក់ទំនងការងារដ៏ជិតស្និទ្ធជាថ្មីឡើងវិញរបស់ឯកឧត្តម វ៉ាង យី ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណភាគីចិន ចំពោះការផ្តល់ការត្រួតពិនិត្យដ៏ពិសេស ដល់ព្រះរាជសុខភាពរបស់**ព្រះករុណាព្រះមហាក្សត្រ** និង **សម្តេចម៉ែ** និងបដិសណ្ឋារ-កិច្ចយ៉ាងកក់ក្តៅថ្វាយចំពោះ**អង្គព្រះមហាក្សត្រ** និង **សម្តេចម៉ែ** ដែលជានិមិត្តរូបបង្ហាញពីការជឿទុកចិត្តយ៉ាងជ្រាលជ្រៅ និងចំណងមិត្តភាពដ៏រឹងមាំរវាងកម្ពុជា និងចិន។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានពិភាក្សាជាមួយឯកឧត្តមឯកអគ្គរដ្ឋទូតចិន អំពីការរៀបចំដំណើរទស្សនកិច្ចផ្លូវការនាពេលខាងមុខរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជាទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដោយបានគូសបញ្ជាក់ពីតម្លៃនៃដំណើរទស្សនកិច្ចនេះ ក្នុងការពង្រឹងបន្ថែមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការត្បូងពេជ្រ សំដៅឆ្ពោះទៅកាន់

អនាគតរួមគ្នាដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍ។ ការរៀបចំដំណើរទស្សនកិច្ចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ក៏ត្រូវបានពិភាក្សាផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូតបានអះអាងពីការប្តេជ្ញាចិត្តក្នុងការអនុវត្តឱ្យបានជោគជ័យនូវកុងសង់ស៊ុស និងការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំប្រទេសទាំងពីរ ដើម្បីជំរុញគម្រោងសំខាន់ៗដូចជា ច្រករបៀងត្រី និងស្រូវ ច្រករបៀងអភិវឌ្ឍន៍ឧស្សាហកម្ម គម្រោងអភិវឌ្ឍន៍កសិកម្មទំនើប និងគម្រោងថាមពលចម្រុះ ក៏ដូចជាការលើកកម្ពស់ការកសាងសហគមន៍កម្ពុជា-ចិន ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់ ក្នុងការកសាងអនាគតរួមគ្នានៅយុគសម័យថ្មី ដោយចាត់ទុកជាគំរូសម្រាប់មនុស្សជាតិ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ចំពោះការរួមចំណែកយ៉ាងសំខាន់របស់ប្រទេសចិនដល់ការអភិវឌ្ឍរបស់កម្ពុជា ជាពិសេសក្នុងវិស័យពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ កសិកម្ម ថាមពល និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ឯកឧត្តមឯកអគ្គរដ្ឋទូត បានរំលឹកឡើងវិញនូវការគាំទ្រឥតងាករេរបស់ចិនសម្រាប់ការអភិវឌ្ឍរបស់កម្ពុជា រួមទាំងគម្រោងព្រែកជីក ហ្វូណន តេជោ និងការប្តេជ្ញាចិត្តរបស់ចិនក្នុងការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត បានសម្តែងការសាទរចំពោះការកំណត់យកឆ្នាំ២០២៥ ជាឆ្នាំទេសចរណ៍កម្ពុជា-ចិន។ ភាគីទាំងពីរបានពិភាក្សាអំពីសារៈសំខាន់នៃការបង្កើនជើងហោះហើរត្រង់ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ដើម្បីស្តារឡើងវិញនូវចំនួនភ្ញៀវទេសចរចិនមកកំសាន្តនៅកម្ពុជាឱ្យដូចមុនមានជំងឺរាតត្បាតកូវីដ-១៩។

ទន្ទឹមនឹងការផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាផលប្រយោជន៍រួម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត បានសង្កត់ធ្ងន់លើការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងវេទិកាអន្តរជាតិ និងបានអះអាងជាថ្មីពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាពក្នុងតំបន់ និងអន្តរជាតិ។ ភាគីទាំងពីរគូសបញ្ជាក់ថែមទៀតពីសារៈសំខាន់នៃការសន្ទនា និងកិច្ចសហប្រតិបត្តិការដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ និងសកលលោក៕

ថ្ងៃអង្គារ ១១រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២៤